## សេចក្ដីសង្ខេបហេតុការណ៍ពិត

បើអ្នកមានចំណែករួមបង់ដំឡៃ ពីព្រោះតែការរកប្រាក់បានរបស់អ្នក ឬបើអ្នកត្រូវបានបដិសេធមិនឲ្យទទួល Medi-Cal ពីព្រោះធ្វើការ អ្នកអាចមានសិទ្ធិទទួលនៅក្រោមកម្មវិធីនេះ ។

បើអ្នកក៏ទទួល Medicare ដែរ នោះការចុះឈ្មោះក្នុងកម្មវិធី Medi-Cal ជនពិការធ្វើការ (Medi-Cal Working Disabled Program) នឹងឲ្យអ្នកមានសិទ្ធិទទួលជាស្វ័យប្រវត្តិ នូវការឧបត្ថម្ភប្រាក់ Medicare ផ្នែក D (ឱសថមានវេជ្ជបញ្ជាដែលគំរោងរ៉ាប់រង រវាង $1 និង $5) សំរាប់អ្នកមានប្រាក់ចំណូលតិច ។



## តើខ្ញុំបានជំរូវឲ្យធ្វើអ្វីខ្លះ?

ដើម្បីឲ្យមានសិទ្ធិទទួលកម្មវិធី Medi-Cal ជនពិការធ្វើការ អ្នកត្រូវ :

- ជាអ្នកមូលដ្ឋាននៃសហរដ្ឋអាមេរិក កំពុងរស់នៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា ។
- ស្របតាមអត្ថន័យនៃភាពពិការ របស់ក្រសួងសូស្យាល់សឺគ្យូរិទី ។
- ធ្វើការពេញពេល ឬកន្លះពេល រួមទាំងការមានការងារខ្លួនឯងដោយមានប្រាក់ដែលអាចរាប់បានស្មើ ឬទាបជាង 250% នៃកំរិតភាពទ័លក្រ រដ្ឋបាលសហព័ន្ធ ។ ពាក្យ “ធ្វើការ” គឺឥតបញ្ជាក់ច្បាស់ សំរាប់គោលបំណងនៃកម្មវិធីនេះឡើយ ហើយក៏ពុំមានសេចក្ដីជំរូវធ្វើការតិចបំផុត ដើម្បីឲ្យមានសិទ្ធិទទួលទេ; តែជាយ៉ាងណាមិញ អ្នកត្រូវតែអាចបង្ហាញភស្ដុតាងថាអ្នកកំពុងធ្វើការ ហើយរកប្រាក់ចំណូលបាន ។

## តើខ្ញុំត្រូវទាក់ទងអ្នកណា សំរាប់ព័ត៌មានបន្ថែមទៀត?

ចូរទាក់ទងការិយាល័យសង្គមកិច្ចនៅខោនធីរបស់អ្នក បើអ្នកគិតថាអ្នកនឹងមានសិទ្ធិទទួលកម្មវិធី Medi-Cal ជនពិការធ្វើការ ឬបើអ្នកចង់បានព័ត៌មានថែមទៀត ។ ព័ត៌មានការទាក់ទងសំរាប់កម្មវិធី អាចរកឃើញនៅវ៉ិបសៃរបស់ផែនការកែលំអបុព្វលាភសុខភាពកាលីហ្វ័រនីញ៉ា (California Health Incentives Improvement Project - CHIIP) នៅឯ **www.chiip.org** ។

អ្នកគ្រោងអត្ថប្រយោជន៍ដែលមានជំរិះវិជ្ជា គឺមានសំរាប់ជួយអ្នក ក្នុងការអនុម័តអំពីប្រាក់ខែរបស់អ្នកនឹងប៉ះពាល់ដល់អត្ថប្រយោជន៍(ជំនួយ)របស់អ្នក ពីរដ្ឋាភិបាលដោយដូចម្ដេច ។ វ៉ិបសៃ **www.db101.org** មានផ្ដល់ព័ត៌មានបច្ចុប្បន្នស្ដីពីកម្មវិធី Medi-Cal ជនពិការធ្វើការ មានព័ត៌មានផ្សេងៗទៀតសំរាប់អ្នកធ្វើការ និងជនពិការកំពុងស្វែងរកការងារធ្វើ មានបញ្ជីឈ្មោះនៃអ្នកគ្រោងអត្ថប្រយោជន៍នៅតាមតំបន់ និងមានប្រដាប់គិតគូរអត្ថប្រយោជន៍ ដែលអាចជួយអ្នកសំរាប់អនុម័តប្រាក់ចំណូលរកបានរបស់អ្នក អាចនឹងប៉ះពាល់ដល់អត្ថប្រយោជន៍ ប្រាក់សុទ្ធរបស់អ្នក ជាយ៉ាងណា ។

ការស្នើសុំព័ត៌មាននេះជាទំរង់ផ្សេងទៀត ឬជាភាសាដទៃទៀត (អេស្ប៉ាញ៉ុល, តាហ្កាឡុក, កូរ៉េ, វៀតណាម, ចិន, រុស្ស៊ី ឬខ្មែរ) ដោយទូរស័ព្ទទៅលេខ (916) 654-8194 ។

**800.695.0350 សំឡេង**

**916.654.9820 TTY**

ការបោះពុម្ពនេះ គឺបានផ្ដល់ថវិកាពេញលេញ ដោយប្រាក់សម្បទានហេដ្ឋារចនាសម្ព័ន្ធ **Medicaid (Medicaid Infrastructure Grant)** ចេញពីមជ្ឈមណ្ឌល សំរាប់សេវា **Medicare** និង **Medicaid** នៃក្រសួងសុខភាព និងសេវាមនុស្ស សហរដ្ឋអាមេរិក លេខសម្បទាន **11P-92399/9-03** ។

**CHIIP** និងដៃគូរបស់ខ្លួន គឺជានិយោជក/អ្នកផ្ដល់ដោយស្មើភាព ។

ការបោះពុម្ព **CHIIP** លេខ **1 (12/2007) Cambodian**

CHIIP
California Health Incentives Improvement Project

**Talent Knows No Limits**
**www.talentknowsnolimits.info**

# កម្មវិធី Medi-Cal ជនពិការធ្វើការ

## Talent Knows No Limits
(កោសល្យមិនស្គាល់ព្រំខណ្ឌទេ)





## តើអ្នកជាមនុស្សពិការ ដែលចង់ធ្វើការឬ?

បើអ្នកមានចំណែករួមបង់ដំឡៃ ពីព្រោះទៃការរកប្រាក់បានរបស់អ្នក ឬបើអ្នកត្រូវបានបដិសេធមិនឲ្យទទួល Medi-Cal ពីព្រោះធ្វើការ អ្នកអាចមានសិទ្ធិទទួលនៅក្រោមកម្មវិធីនេះ ។

បើអ្នកក៏ទទួល Medicare ដែរ នោះការចុះឈ្មោះក្នុងកម្មវិធី Medi-Cal ជនពិការធ្វើការ (Medi-Cal Working Disabled Program) នឹងឲ្យអ្នកមានសិទ្ធិទទួលជាស្វ័យប្រវត្តិ នូវការឧបត្ថម្ភប្រាក់ Medicare ផ្នែក D (ឱសថមានវេជ្ជបញ្ជាដែលគំរោងរ៉ាប់រង រវាង $1 និង $5) សំរាប់អ្នកមានប្រាក់ចំណូលតិច ។

បើអ្នកជាមនុស្សពិការ ហើយអ្នកធ្វើការពេញពេល ឬកន្លះពេល ឬក៏មានការងារខ្លួនឯង នោះអ្នកអាចនឹងទទួលការរ៉ាប់រងសុខភាពពី Medi-Cal បាន ។ កម្មវិធី Medi-Cal ជនពិការធ្វើការ អនុញ្ញាតឲ្យអ្នករកប្រាក់បានរហូតដល់ទៅ $52,092* ឬច្រើនជាង ក្នុងមួយឆ្នាំ ឋានៈជាបុគ្គលម្នាក់ និងនៅតែអាចទទួលការរ៉ាប់រង Medi-Cal មានដំឡៃគួរសម ។

## តើ Medi-Cal ជាអ្វី?

Medi-Cal គឺជាឈ្មោះរបស់កាលីហ្វ័រនីញ៉ា សំរាប់កម្មវិធី Medicaid នៃរដ្ឋបាលសហព័ន្ធ ។ Medi-Cal ផ្តល់ការរ៉ាប់រងសុខភាព (រួមទាំង ខាងរោគា, ធ្មេញ, ភ្នែក និងសេវាជំនួយផ្ទាល់ខ្លួន) សំរាប់គ្រួសារមានប្រាក់ចំណូលតិច និងមនុស្សដែលពិការ ខ្វះខាតការរ៉ាប់រងសុខភាពគ្រប់គ្រាន់ ។

## តើហេតុអ្វីបានជាការបន្តរ៉ាប់រងសុខភាព មានសារៈសំខាន់ម្ល៉េះ?

ការរ៉ាប់រងសុខភាព ធ្វើឲ្យប្រាកដថាអ្នកទទួលការថែទាំជាហូរហែ នៅពេលអ្នកត្រូវការវា ដោយអ្នកផ្តល់ការថែទាំសុខភាពដែលដឹងប្រវត្តិសុខភាព របស់អ្នក ។ ការរ៉ាប់រងសុខភាពផ្តល់សេវាជាបង្ការ និងអនុញ្ញាតឲ្យអ្នកទទួលការថែទាំ នៅពេលណាអ្នកឈឺថ្កាត់ ឬមានរបួស ។

## តើខ្ញុំអាចរកប្រាក់បានចំនួនប៉ុន្មាន?

ឧទាហរណ៍ ឋានៈជាបុគ្គលនៅលីវ អ្នកអាចរកប្រាក់បានប្រហែល $4,300* ក្នុងមួយខែ នៃប្រាក់ថ្លៃឈ្នួលរួម ក្នុងឆ្នាំ 2007 ហើយមានសិទ្ធិទទួលការរ៉ាប់រងសុខភាពពី Medi-Cal ពីព្រោះកម្មវិធីនេះមិនរាប់ប្រហែលពាក់កណ្តាលនៃការរកប្រាក់បានរបស់អ្នក ។

ចំនួន $85 នឹងត្រូវបានដកចេញពីចំនួនសរុបនៃប្រាក់រកបានជាប្រចាំខែ រួចហើយតែពាក់កណ្តាលនៃចំនួននៅសល់ទេ ដែលត្រូវបានចាត់ទុកជាប្រាក់ចំណូលរកបាន ដែលអាចរាប់បាន នៅពេល Medi-Cal សំរេចថាអ្នកមានសិទ្ធិទទួល ។ អ្នកក៏អាចដកការចំណាយទៅលើការងាររបស់អ្នក ជាប់ទាក់ទងចំពោះភាពពិការរបស់អ្នកដែរ ។

## តើមានថ្លៃបង់ធានារ៉ាប់រងឬទេ?

អ្នកដែលចុះឈ្មោះក្នុងកម្មវិធី Medi-Cal ជនពិការធ្វើការ បង់ថ្លៃធានារ៉ាប់រងបន្តិចបន្តួច ដោយយោងទៅលើប្រាក់ចំណូលរកបាន ដែលអាចរាប់បាន ។

*សំរាប់កំរិតប្រាក់ចំណូលនៅពេលបច្ចុប្បន្ន សូមមើលផ្នែក Medi-Cal នៅ **www.db101.org** ។

ប្រាក់ពិការ ដូចជាការធានារ៉ាប់រងភាពពិការ សូស្យាល់សឹគ្យូរិទី (Social Security Disability Insurance - SSDI) គឺមិនរាប់ជាប្រាក់ចំណូល សំរាប់កម្មវិធីនេះឡើយ ។

សំរាប់ជាឧទាហរណ៍ :

- បុគ្គលម្នាក់ ដែលប្រាក់ចំណូលរបស់គេ មានរវាង $1,287 និង $1,485 (ប្រហែល) ត្រូវបង់ថ្លៃធានារ៉ាប់រង $25 ។
- បុគ្គលពីរនាក់ ដែលប្រាក់ចំណូលរបស់គេ មានរវាង $1,287 និង $1,485 (ប្រហែល) ត្រូវបង់ថ្លៃធានារ៉ាប់រង $40 ។

ការប្រើប្រដាប់គិតលេខ Medi-Cal សំរាប់ជនពិការធ្វើការនៅ **www.db101.org** អ្នកអាចគិតចំនួនថ្លៃបង់ធានារ៉ាប់រងជាប្រចាំខែដែលអ្នកនឹងត្រូវបង់ប៉ុន្មាន ។

## តើខ្ញុំអាចទទួលជំនួយផ្ទាល់ខ្លួន នៅកន្លែងខ្ញុំធ្វើការបានឬទេ?

អ្នកអាចនឹងមានសិទ្ធិទទួលជំនួយផ្ទាល់ខ្លួន តាមរយៈសេវាការគាំទ្រនៅក្នុងផ្ទះ (In-Home Supportive Services-IHSS) របស់កម្មវិធី Medi-Cal ។ Medi-Cal គឺប្លែកពីគេ បើប្រៀបធៀបទៅនឹងការរ៉ាប់រងសុខភាពផ្សេងៗទៀត ដែលផ្តល់ថវិកាសំរាប់សេវាជំនួយផ្ទាល់ខ្លួន តាមរយៈកម្មវិធី IHSS ។

ដើម្បីប្រើសេវាជំនួយផ្ទាល់ខ្លួននៅកន្លែងធ្វើការ អ្នកត្រូវតែមានសិទ្ធិទទួលកម្មវិធី IHSS នៅផ្ទះជាមុនសិន ។ បន្ទាប់ពីត្រូវបានយល់ព្រមសំរាប់ IHSS រួចហើយ អ្នកអាចផ្លាស់ប្តូរម៉ោងសេវាខ្លះ ពីផ្ទះទៅកន្លែងធ្វើការបាន ។

ច្បាប់រដ្ឋកាលីហ្វ័រនីញ៉ា អនុញ្ញាតឲ្យបុគ្គលដែលពិការ ប្រើម៉ោងសេវា IHSS ដើម្បីទទួល រក្សា ឬត្រឡប់ទៅធ្វើការវិញ ។ អ្នកធ្វើការខាងសង្គមកិច្ចនៅខោនធី អាចផ្តល់ឱវាទអ្នកអំពីកម្មវិធី IHSS ។



## តើខ្ញុំត្រូវបានអនុញ្ញាតអ្វីខ្លះ?

- អ្នកអាចមានប្រាក់ $2,000 ឋានៈជាបុគ្គលម្នាក់ ឬ $3,000 សំរាប់បុគ្គលពីរនាក់ដែលរៀបការ ដោយមានទ្រព្យសម្បត្តិផ្ទាល់ខ្លួន រួមទាំង ប្រាក់សុទ្ធ ស្តុក និងវត្ថុខ្លះផ្សេងៗទៀត ។
- អ្នកអាចមានឡានមួយគ្រឿង និងផ្ទះដែលអ្នករស់នៅ ។
- អ្នកអាចមានកុងប្រាក់សន្សំទុកសំរាប់រីទៃរ៉េតរៀងខ្លួន (Individual Retirement Accounts - IRA), កុងវឌ្ឍនកម្មរៀងខ្លួន (Individual Development Accounts - IDA), គំរោងការរីទៃរ៉េត, និងគំរោងការលើកពេលសងប្រាក់ ។ ការសន្សំប្រាក់ប្រភេទទាំងនេះគឺបានអនុគ្រោះ ហើយមិនបានរាប់នៅក្នុងកម្មវិធីនេះទេ ។
- អ្នកអាចទទួលប្រាក់ពិការ ពីក្រសួងសូស្យាល់សឹគ្យូរិទ ពីរដ្ឋ ពីក្រុមហ៊ុនធានារ៉ាប់រងភាពពិការឯកជន ឬពីផ្នែកការសងប្រាក់ឲ្យកម្មករព្រោះមានគ្រោះថ្នាក់នៅការដ្ឋាន ។ ប្រាក់ពិការ គឺបានអនុគ្រោះ ហើយមិនបានរាប់នៅក្នុងកម្មវិធីនេះទេ ។ តែជាយ៉ាងណាមិញ ប្រាក់ពិការរបស់អ្នកអាចបានប៉ះទង្គិច ដោយប្រាក់ចំណូលដែលអ្នករកបានពីកន្លែងធ្វើការ ។ សំរាប់ព័ត៌មានបន្ថែមស្តីអំពីការលើកទឹកចិត្តធ្វើការសូស្យាល់សឹគ្យូរិទី សូមមើល **www.db101.org** ។